RHODE ISLAND DEPARTMENT OF HEALTH

# អ្វីដែលត្រូវយល់ដឹងអំពីជំងឺកាមរោគ

## តើជំងឺកាមរោគគឺជាអ្វី?

ជំងឺកាមរោគ **(Sexually Transmitted Infections, STIs)** គឺជាជំងឺឆ្លង ដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមរយៈការរួមភេទ។

## ហេតុអ្វីបានជាការយល់ដឹងពីស្ថានភាពជំងឺកាមរោគរបស់អ្នកមានសារៈសំខាន់

- ជារឿយៗជំងឺកាមរោគមិនបង្ហាញរោគសញ្ញាទេ ប៉ុន្តែអាចបណ្តាលឱ្យមានបញ្ហាសុខភាពធ្ងន់ធ្ងរ។
- អ្នកដែលសកម្មខាងផ្លូវភេទអាចឆ្លងជំងឺកាមរោគបាន។
- ការធ្វើតេស្ត និងការព្យាបាលទាន់ពេលវេលាអាចការពារសុខភាពរបស់អ្នក និងដៃគូរបស់អ្នកបាន។

## របៀបរក្សាសុវត្ថិភាព

- ប្រើស្រោមអនាម័យរាល់ពេលដែលអ្នករួមភេទ ដើម្បីការពារការមានផ្ទៃពោះ និងជំងឺកាមរោគ។ អ្នកអាចបញ្ជាទិញស្រោមអនាម័យដោយឥតគិតថ្លៃតាមប្រៃសណីយ៍ពីក្រសួងសុខាភិបាលរដ្ឋ Rhode Island ឬស្វែងរកវានៅតាមទីតាំងសហគមន៍។
- សួរគ្រូពេទ្យរបស់អ្នកអំពីថ្នាំ  Doxy PEP – លេបថ្នាំអង់ទីប៊ីយូទិក doxycycline ក្នុងរយៈពេល 72 ម៉ោងបន្ទាប់ពីការរួមភេទដោយមិនបានការពារ ដើម្បីបង្ការជំងឺកាមរោគ។ អ្នកក៏អាចសួរគ្រូពេទ្យរបស់អ្នកអំពីថ្នាំ PrEP, ដែលជាថ្នាំផ្សេងមួយទៀត ដើម្បីការពារមេរោគអេដស៍បានដែរ។
- ទទួលការធ្វើតេស្តជំងឺកាមរោគជាទៀងទាត់ ជាពិសេសប្រសិនបើអ្នកមានដៃគូច្រើន។
- និយាយដោយបើកចំហជាមួយដៃគូរបស់អ្នក និងគ្រូពេទ្យ ឬអ្នកជំនាញថែទាំសុខភាពអំពីសុខភាពផ្លូវភេទ។
- កំណត់ចំនួនដៃគូផ្លូវភេទរបស់អ្នក។
- សួរអ្នកជំនាញថែទាំសុខភាព ថាតើការចាក់វ៉ាក់សាំងប្រឆាំងនឹងមេរោគ HPV, mpox, រលាកស្រោមខួរ ឬជំងឺរលាកថ្លើមប្រភេទ A និងជំងឺរលាកថ្លើមប្រភេទ B គឺត្រឹមត្រូវសម្រាប់អ្នកដែរឬទេ។
- ទទួលការព្យាបាល – ជំងឺកាមរោគភាគច្រើនអាចព្យាបាលបាន ឬព្យាបាលដោយប្រើថ្នាំ។

**សូមចងចាំ**

ជំងឺកាមរោគគឺជាជំងឺធម្មតា អាចព្យាបាលបាន និងអាចបង្ការបាន។
ការយល់ដឹងពីស្ថានភាពជំងឺកាមរោគរបស់អ្នកគឺជាវិធានការដំបូងគេដើម្បីការពារសុខភាពរបស់អ្នក។

## ស្វែងយល់បន្ថែម

- ស្វែងរកព័ត៌មានបន្ថែមអំពីជំងឺកាមរោគ ស្វែងរកទីតាំងផ្តល់ស្រោមអនាម័យដោយឥតគិតថ្លៃ ស្វែងរកសេវាសុខភាព និងស្វែងរកជម្រើសធ្វើតេស្តដោយចូលទៅកាន់គំណ health.ri.gov/youoptions។ អ្នកក៏អាចហៅទូរសព្ទទៅ ក្រសួងសុខាភិបាលរដ្ឋ Rhode Island សម្រាប់ការជួយស្វែងរកសេវាផ្សេងៗ តាមរយៈលេខ 401-222-5960 បានដែរ។
- ស្វែងរកព័ត៌មានសម្រាប់យុវវ័យអំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ រួមទាំងការស្វែងរកស្រោមអនាម័យ និងការថែទាំដោយឥតគិតថ្លៃនៅរដ្ឋ Rhode Island នៅលើកម្មវិធីRIghtToKnow app។

វាមានសារៈសំខាន់ក្នុងការទទួលការថែទាំដែលអ្នកត្រូវការដើម្បីឱ្យមានសុខភាពល្អ។ ប្រសិនបើអ្នកមានសំណួរផ្លូវច្បាប់ទាក់ទងនឹងសិទ្ធិអន្តោប្រវេសន៍ក្នុងការចូលប្រើសេវាថែទាំសុខភាពដោយសម្ងាត់ សូម ទូរសព្ទទៅ Dorcas International តាមរយៈលេខ 401-784-8607។

DORCAS INTERNATIONAL
INSTITUTE OF RHODE ISLAND